**សុន្ទរកថារបស់ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីសម្ពោធអគារជំងឺទូទៅ ក្នុងមន្ទីរពេទ្យបង្អែកកោះអណ្ដែត នៃស្រុកប្រតិបត្តិកោះអណ្ដែត ខេត្តតាកែវ**

ថ្ងៃទី០៦ ខែ តុលា ឆ្នាំ ២០១៥

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!
- សូមគោរព **ឯកឧត្តម សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី
- សូមគោរព **ឯកឧត្តម ឡាយ វណ្ណៈ** អភិបាលខេត្តតាកែវ
- សូមគោរព **លោកវេជ្ជបណ្ឌិត ហែម សារ៉េត** ប្រធានមន្ទីរសុខាភិបាលខេត្តតាកែវ
- សូមគោរព អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានមកចូលរួមពិធីសម្ពោធអគារជំងឺទូទៅក្នុងមន្ទីរពេទ្យបង្អែកកោះអណ្តែត នៃស្រុកប្រតិបត្តិកោះអណ្តែតនេះ ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងនៅក្នុងការកសាងឡើងវិញ និងការអភិវឌ្ឍប្រទេសរបស់ខ្លួន ហើយក៏បានធ្វើអោយសម្រេចនូវអត្រាកំណើនសេដ្ឋកិច្ចខ្ពស់បំផុតរបស់ខ្លួន ស្មើនឹងបណ្តាប្រទេសកំពុងរីកចំរើនក្នុងតំបន់អាស៊ានផងដែរ។ នៅក្នុងវិស័យសុខាភិបាលទាំងបរិមាណនិងគុណភាពមានភាពប្រសើរឡើងយ៉ាងខ្លាំងផងដែរ តាមរយៈកិច្ចសហប្រតិបត្តិការរវាងក្រសួងសុខាភិបាល និងសហគមន៍អន្តរជាតិ។

រដ្ឋាភិបាលជប៉ុន បាននឹងកំពុងបន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីអភិវឌ្ឍន៍លើគ្រប់វិស័យដោយផ្តោតជាសំខាន់លើការកែលម្អនូវអគារថែទាំវេជ្ជសាស្ត្រ។

គម្រោងនេះ គឺដើម្បីសាងសង់អគារជម្ងឺទូទៅ និងបំពាក់ទៅដោយគ្រែអ្នកជម្ងឺ នៅក្នុងមន្ទីរពេទ្យបង្អែកកោះអណ្តែត នៃស្រុកប្រតិបត្តិកោះអណ្តែត។ ដោយសារតែចំនួនអ្នកជម្ងឺ នៅក្នុងមន្ទីរពេទ្យបង្អែកកោះអណ្តែតនេះ មានការកើនឡើងយ៉ាងឆាប់រហ័សនៅប៉ុន្មានឆ្នាំថ្មីៗនេះ ដែលធ្វើអោយអ្នកជម្ងឺនៅរាយប៉ាយពាសពេញមន្ទីរពេទ្យ ហើយការឆ្លងជំងឺ ក៏មានអត្រាខ្ពស់ដែលគួរអោយកត់សម្គាល់ផងដែរ។ អគារជម្ងឺទូទៅថ្មីនេះ ត្រូវបានឧបត្ថម្ភគាំទ្រដោយជំនួយឥតសំណងទ្រង់ទ្រាយតូច(គូសាណុណេ)របស់ជប៉ុន ដែលអាចអោយអ្នកជំងឺកាន់តែច្រើនឡើងទទួលបានការព្យាបាលជំងឺប្រកបដោយសុវត្ថិភាព និងក្នុងបរិស្ថានប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ជាងមុន។ ដោយហេតុនេះ យើងសង្ឃឹមថាគម្រោងនេះនឹងរួមចំណែកជួយកែលម្អធ្វើអោយប្រសើរឡើងនូវស្ថានភាពសុខភាពនៅក្នុងតំបន់។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អគារជំងឺទូទៅថ្មីនេះ នឹងពង្រីកការផ្តល់សេវាសុខភាពបន្ថែមទៀត ក្នុងខេត្តតាកែវ ហើយជាលទ្ធផលប្រជាពលរដ្ឋជាច្រើន នឹងទទួលបានអត្ថប្រយោជន៍ពីសេវាសុខភាពដែលផ្តល់ដោយមន្ទីរពេទ្យល្អប្រសើរជាងមុន ។ ខ្ញុំសង្ឃឹមថា មន្ទីរពេទ្យនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវ និងប្រើប្រាស់អោយបានយូរអង្វែង ដើម្បីទុកជានិមិត្តរូបនៃទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណ!**